**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**..៣៧..អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ប្រាក់តំបន់សម្រាប់មន្ត្រីរាជការស៊ីវិលក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ មានគោលបំណងរៀបចំនិងកំណត់ប្រាក់តំបន់សម្រាប់មន្ត្រីរាជការស៊ីវិលក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ដើម្បីពង្រឹងការផ្តល់សេវាអប់រំនិងសេវាសុខាភិបាលនៅតំបន់ជួបការលំបាកនិងតំបន់ដាច់ស្រយាល ។

**មាត្រា២ ..**

អនុក្រឹត្យនេះ មានគោលដៅ ៖

- កំណត់គោលការណ៍និងលក្ខណៈវិនិច្ឆ័យនៃតំបន់ជួបការលំបាកនិងតំបន់ដាច់ស្រយាល
- កំណត់ប្រាក់តំបន់សម្រាប់មន្ត្រីរាជការស៊ីវិលក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល
- ពង្រឹងប្រសិទ្ធភាពនៃការពង្រាយមន្ត្រីរាជការស៊ីវិល និង លើកទឹកចិត្តមន្ត្រីរាជការស៊ីវិលក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ដែលបម្រើការងារនៅតំបន់ជួបការលំបាកនិងតំបន់ដាច់ស្រយាល។

**មាត្រា៣ ..**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីរាជការស៊ីវិលក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល។

## ជំពូកទី២
## ការកំណត់និងការទទួលស្គាល់មន្ត្រីរាជការ ក្នុងតំបន់ជួបការលំបាកនិងតំបន់ដាច់ស្រយាល

**មាត្រា៤ ..**

ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវកំណត់គោលការណ៍និងលក្ខខណ្ឌវិនិច្ឆ័យ ឱ្យបានច្បាស់លាស់ក្នុងការកំណត់តំបន់ជួបការលំបាកនិងតំបន់ដាច់ស្រយាល ដោយផ្អែកលើស្ថានភាពផ្នែកសង្គមនិងសេដ្ឋកិច្ចជាក់ស្តែងនៃទីតាំងភូមិសាស្ត្រនីមួយៗ ព្រមទាំងកំណត់ចំនួនមន្ត្រីរាជការក្នុងវិស័យអប់រំ និង វិស័យសុខាភិបាលដែលត្រូវទទួលប្រាក់តំបន់នៅតាមទីតាំងភូមិសាស្ត្រជាក់លាក់ឱ្យបានរួចរាល់មុនខែមេសានៃឆ្នាំនីមួយៗ ដោយត្រូវអនុវត្តគិតចាប់ពីខែមករាដល់ខែធ្នូ។

**មាត្រា៥ ..**

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវសម្រេចតាមរយៈប្រកាសរបស់ក្រសួង ដើម្បីកំណត់ទីតាំងភូមិសាស្ត្រជាក់លាក់នៅតាមរាជធានី ខេត្ត ជាតំបន់ជួបការលំបាកនិងតំបន់ដាច់ស្រយាលក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល តាមសំណើរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡានិងប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត បន្ទាប់ពីបានស្នើសុំយោបល់ពីគណៈអភិបាលរាជធានី ខេត្ត ផ្អែកលើករណីពាក់ព័ន្ធនីមួយៗសម្រាប់រយៈពេលមួយឆ្នាំម្តង ។

**មាត្រា៦ ..**

ប្រធានមន្ទីររាជធានី ខេត្តនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចេញសេចក្តីសម្រេចទទួលស្គាល់ឈ្មោះមន្ត្រីរាជការក្នុងវិស័យអប់រំនិងវិស័យសុខាភិបាលដែលត្រូវទទួលប្រាក់តំបន់ បន្ទាប់ពីទទួលបានទិដ្ឋាការពីមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត។

## ជំពូកទី៣
## ការកំណត់ប្រាក់តំបន់

**មាត្រា៧ ._**

ប្រាក់តំបន់ គឺជាប្រាក់សម្រាប់ឧបត្ថម្ភប្រចាំខែ ជូនដល់មន្ត្រីរាជការស៊ីវិលក្នុងវិស័យអប់រំនិងវិស័យសុខាភិបាលដែលកំពុងបម្រើការងារនៅតាមទីតាំងភូមិសាស្ត្រដែលត្រូវបានកំណត់ជាតំបន់ជួបការលំបាកនិងតំបន់ដាច់ស្រយាលដូចមានចែងក្នុងមាត្រា៤និងមាត្រា៥ខាងលើ។

**មាត្រា៨ ._**

ប្រាក់តំបន់ ពុំមានលក្ខណៈជាអចិន្ត្រៃយ៍ឡើយនិងត្រូវអនុវត្តអនុលោមបញ្ញត្តិនៃមាត្រា៤និងមាត្រា៥ខាងលើ។ ការបើកផ្តល់ប្រាក់តំបន់ជូនមន្ត្រីរាជការស៊ីវិលដែលកំពុងបម្រើការងារនៅតាមតំបន់ជួបការលំបាកនិងតំបន់ដាច់ស្រយាល ត្រូវអនុវត្តតាមតារាងទូទាត់បៀវត្សមន្ត្រីរាជការស៊ីវិលគ្រប់គ្រងដោយក្រសួងមុខងារសាធារណៈ។

**មាត្រា៩ ._**

ប្រាក់តំបន់ ត្រូវបានកំណត់ដូចខាងក្រោម ៖

| ល.រ | បរិយាយ | កម្រិតប្រាក់តំបន់ប្រចាំខែ(រៀល) |
|---|---|---|
| ១ | តំបន់ជួបការលំបាក | ៨០ ០០០ |
| ២ | តំបន់ដាច់ស្រយាលប្រភេទ១ | ១០០ ០០០ |
| ៣ | តំបន់ដាច់ស្រយាលប្រភេទ២ | ១២០ ០០០ |

តំបន់ដាច់ស្រយាលប្រភេទ១ ត្រូវបានប្រើប្រាស់ជំនួសវាក្យស័ព្ទតំបន់ដាច់ស្រយាលទីរួមខេត្ត និងតំបន់ដាច់ស្រយាលប្រភេទ២ ត្រូវបានប្រើប្រាស់ជំនួសវាក្យស័ព្ទតំបន់ដាច់ស្រយាលជនបទ។

**មាត្រា១០ ._**

កម្រិតប្រាក់តំបន់ដែលមានកំណត់ក្នុងមាត្រា៩ខាងលើ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ តទៅ។

**មាត្រា១១ ._**

ការកែប្រែប្រាក់តំបន់ ត្រូវធ្វើឡើងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**មាត្រា១២ ._**

លិខិតបទដ្ឋានគតិយុត្តជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រង ការកំណត់តំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាល និងការកំណត់ចំនួនមន្ត្រីរាជការដែលត្រូវទទួលប្រាក់តំបន់របស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបន្តអនុវត្តត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០១៥ ប៉ុណ្ណោះ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា១៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ